មជ្ឈមណ្ឌលឯកសារកម្ពុជា

# ការបង្ហាអំពើប្រល័យពូជសាសន៍ ៖ គម្រោងស្តីពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ វគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិស្តីពីការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅថ្នាក់មធ្យមសិក្សា

២៩ មិថុនា-៧ កក្កដា ២០០៩

បណ្ណាល័យព្រឹទ្ធសភា ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

## ការត្រិះរិះពិចារណា ៖ សិល្បៈនៃការសួរសំណួរបែបសូក្រាត

(ដោយ Richard Paul and Linda Elder)

ការសួរសំណួរបែបសូក្រាត គឺជាវិធីសាស្ត្រសួរសំណួរម៉្យាងដែលអាចប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាច្រើនទិសដៅ និងបម្រើគោលបំណងជាច្រើនដូចជា ដើម្បីស្វែងរកអំពីគំនិតស្មុគស្មាញ ដើម្បីស្វែងរកការពិតនៃបញ្ហា ដើម្បីកត់សម្គាល់បញ្ហាមកដោះស្រាយ ដើម្បីស្វែងយល់អំពីការសន្និដ្ឋាន ដើម្បីវិភាគទស្សនៈ ដើម្បីបែងចែកឲ្យច្បាស់អ្វីដែលបានដឹង និងអ្វីដែលមិនទាន់បានដឹង និងចុងក្រោយដើម្បីតាមដានអំពីលទ្ធផលជាលក្ខណៈតក្កវិទ្យានៃគំនិត ។ ចំណុចសំខាន់ក្នុងការបែងចែកវិធីសាស្ត្រសួរសំណួរបែបសូក្រាតឲ្យដាច់ពីការសួរសំណួរបែបផ្សេងទៀតគឺថា ការសួរសំណួរបែបសូក្រាតមានលក្ខណៈជាប្រព័ន្ធ មានមូលដ្ឋានទ្រឹស្តីច្បាស់លាស់ និងស៊ីជម្រៅ ។ លើសពីនេះ ការសួរសំណួរបែបសូក្រាតផ្តោតទៅលើទស្សនៈ ទ្រឹស្តី និងបញ្ហាជាមូលដ្ឋាន ។

គ្រូបង្រៀន សិស្ស ឬអ្នកណាផ្សេងទៀតដែលមានចំណាប់អារម្មណ៍ក្នុងការស្វែងយល់អំពីការគិតពិចារណាក្នុងកម្រិតជ្រៅអាចនឹងគួរបង្កើតសំណួរបែបសូក្រាត និងចូលរួមនៅក្នុងការសន្ទនាបែបសូក្រាត ។ គោលបំណងនៃការសួរសំណួរបែបសូក្រាតនៅក្នុងការបង្ហាត់បង្រៀនគឺដើម្បីស្វែងយល់អំពីការគិតគូររបស់សិស្ស ដើម្បីកំណត់អំពីការយល់ដឹងរបស់សិស្សទៅលើប្រធានបទណាមួយ ដើម្បីបង្កើតសំណួរបែបសូក្រាតដល់សិស្ស ដើម្បីជួយសិស្សវិភាគអំពីទស្សនៈមួយ ឬវិភាគអំពីខ្សែសង្វាក់នៃការបង្កើតហេតុផល ។ នៅក្នុងការវិភាគចុងក្រោយ សិស្សទាំងឡាយគួររៀនអំពីវិធីសាស្ត្រនៃការសួរសំណួរបែបសូក្រាត ដើម្បីឲ្យខ្លួនអាចប្រើប្រាស់វិធីសាស្ត្រនេះនៅក្នុងការបង្កើតហេតុផលពន្យល់ទៅលើបញ្ហាស្មុគស្មាញ នៅក្នុងការស្វែងយល់ និងវាយតម្លៃផ្នត់គំនិតរបស់អ្នកផ្សេង និងនៅក្នុងការកំណត់អំពីលទ្ធផលនៃការគិតរបស់ខ្លួន និងរបស់អ្នកផ្សេង ។

នៅក្នុងការបង្ហាត់បង្រៀន ការសួរសំណួរបែបសូក្រាតអាចត្រូវបានប្រើប្រាស់ដើម្បីគោលបំណងយ៉ាងហោចចំនួនពីរ ៖

- ដើម្បីស្វែងយល់ឲ្យបានជ្រាលជ្រៅទៅលើការគិតពិចារណារបស់សិស្ស និងដើម្បីជួយសិស្សបែងចែកឲ្យដាច់អំពីអ្វីដែលខ្លួនដឹង ឬយល់ចេញពីអ្វីដែលខ្លួនមិនបានដឹង ឬយល់ (ការធ្វើបែបនេះជួយសិស្សឲ្យដឹងពីចំណេះដឹងខ្លួនឯង) ។

- ដើម្បីជួយបង្កើនលទ្ធភាពកូនសិស្សឲ្យសួរសំណួរបែបសូក្រាត និងជួយសិស្សឲ្យរៀនសូត្រដឹងអំពីវិធីសាស្រ្តប្រើប្រាស់ការសន្ទនាបែបសូក្រាត ដើម្បីឲ្យសិស្សអាចប្រើប្រាស់វិធីសាស្រ្តទាំងនេះនៅក្នុងជីវភាពប្រចាំថ្ងៃ (ក្នុងការសួរខ្លួនឯង និងសួរអ្នកដទៃ) ។ ដើម្បីបម្រើគោលបំណងនេះ យើងត្រូវធ្វើយ៉ាងណាបង្កើតជាវិធីសាស្រ្តសួរសំណួរដែលគ្រូបង្រៀនចង់ឲ្យកូនសិស្សធ្វើតាម និងអនុវត្ត ។ លើសពីនេះ កូនសិស្សទាមទារឲ្យមានការណែនាំដោយផ្ទាល់ពីគ្រូទាក់ទងទៅលើការបង្កើត និងសួរសំណួរជ្រៅ ។

ការសួរសំណួរបែបសូក្រាតបង្រៀនសិស្សពីសារប្រយោជន៍នៃការសួរសំណួរនៅក្នុងការរៀនសូត្រ (តាមការពិត សូក្រាតខ្លួនឯងបានគិតថា ការសួរសំណួរគឺជាវិធីសាស្រ្តបង្រៀនដ៏ល្អតែមួយគត់) ។ វិធីសាស្រ្តនេះបង្រៀនឲ្យយល់អំពីភាពខុសគ្នារវាងការគិតដែលមានលក្ខណៈជាប្រព័ន្ធ និងការគិតដែលមានលក្ខណៈរាយប៉ាយ ។ វិធីសាស្រ្តនេះបង្កឲ្យមានការស្វែងយល់ និងចង់ដឹងឲ្យបានកាន់តែជ្រៅ ។ វាឲ្យតម្លៃទៅលើការអភិវឌ្ឍនៃមនុស្សដែលពូកែសួរ ដើម្បីរៀនចេះដឹងឲ្យកាន់តែជ្រាលជ្រៅ ។

សិល្បៈនៃការសួរសំណួរបែបសូក្រាត មានទំនាក់ទំនងយ៉ាងជ្រាលជ្រៅទៅនឹងវិធីសាស្រ្តនៃការបង្រៀនឲ្យចេះត្រិះរិះពិចារណា ពីព្រោះថា សិល្បៈនៃការសួរសំណួរវាមានតម្លៃខ្លាំងចំពោះការបង្កើតឲ្យមានគំនិតដ៏ឈ្លាសវៃ ។ គេប្រើប្រាស់ពាក្យសូក្រាតមកភ្ជាប់ជាមួយសិល្បៈនៃការសួរសំណួរ គឺចង់បញ្ជាក់លក្ខណៈជាប្រព័ន្ធ ជម្រៅ និងការចាប់អារម្មណ៍ខ្លាំងនៅក្នុងការវិភាគអំពីការពិត ឬគំនិតដែលអាចជាការពិត ។

វិធីសាស្រ្តនៃការត្រិះរិះពិចារណា និងវិធីសាស្រ្តនៃការសួរសំណួរបែបសូក្រាតមានគោលបំណងរួមមួយ ។ វិធីសាស្រ្តនៃការត្រិះរិះពិចារណាផ្តល់ជាឧបករណ៍ដ៏សំខាន់មួយសម្រាប់ស្វែងយល់អំពីដំណើរការនៃគំនិត (ក្នុងការយល់ដឹងអំពីអត្ថន័យ និងការពិត) ។ ការសួរសំណួរបែបសូក្រាតប្រើប្រាស់ឧបករណ៍ទាំងនេះនៅក្នុងការបង្កើតសំណួរដែលមានប្រយោជន៍នៅក្នុងការស្វែងយល់អំពីអត្ថន័យ និងការពិត ។ គោលដៅសំខាន់នៃវិធីសាស្រ្តត្រិះរិះពិចារណា ដើម្បីបង្កើតជាកម្រិតមួយទៀតនៃការគិតដែលមានសណ្ឋានជាសំឡេងនៃហេតុផលដ៏សំខាន់មួយនៅក្នុងគំនិត ។ ការពិភាក្សាបែបសូក្រាតបង្កឲ្យមានសំឡេងនៅក្នុងគំនិតទាំងនោះ តាមរយៈការផ្តោតយ៉ាងច្បាស់លាស់ទៅលើការសួរសំណួរដែលមានវិធីសាស្រ្តត្រឹមត្រូវ និងផ្តោតទៅលើខ្លួនឯង ។

នៅក្នុងទំព័រនេះ និងទំព័រក្រោយ យើងផ្តោតទៅលើធាតុទាំងឡាយនៃការសន្ទនាបែបសូក្រាត ឧបករណ៍ដែលវិធីសាស្ត្រនៃការគិតពិចារណាបង្កើតឲ្យមានការងាយស្រួលដល់ការសន្ទនាបែបសូក្រាត និង សារប្រយោជន៍នៃការសួរសំណួរនៅក្នុងការបង្កឲ្យមានការគិតគូរដែលមានសណ្ឋានច្បាស់លាស់ ។

## ចំណាត់ថ្នាក់នៃការសួរសំណួរបែបសូក្រាតផ្អែកទៅលើវិធីសាស្ត្រនៃការត្រិះរិះពិចារណា

ដើម្បីបង្កើតសំណួរដែលស្វែងយល់អំពីការគិតពិចារណាដ៏ល្អបំផុត អ្នកសួរត្រូវយល់អំពីដំណើរការនៃការគិតពិចារណា ថាតើវាមានលក្ខណៈយ៉ាងដូចម្តេច ហើយវាគួរត្រូវបានវិភាគតាមវិធីណា ។ ការត្រិះរិះពិចារណាផ្តល់ជាឧបករណ៍ដើម្បីវិភាគ និងវាយតម្លៃខ្សែសង្វាក់នៃការផ្តល់ហេតុផល ។ នេះគឺជាមូលហេតុដែលការស្វែងយល់អំពីការត្រិះរិះពិចារណាមានលក្ខណៈសំខាន់ក្នុងការសន្ទនាបែបសូក្រាតដែលមានលទ្ធផលខ្ពស់ ។ ខាងក្រោមនឹងផ្តោតទៅលើការវិភាគជាខ្សែសង្វាក់នៃការលើកហេតុផល ។

## សំណួរដែលសួរអំពីផ្នែកមួយនៃការគិតគូរ

តាមរយៈការប្រើសំណួរដែលមានលក្ខណៈនៅក្នុងការសន្ទនាបែបសូក្រាត វាមានលក្ខណៈសំខាន់នៅក្នុងការយល់ដឹង និងក្នុងការវិភាគអំពីខ្សែសង្វាក់នៃការលើកហេតុផល ។ ដើម្បីវិភាគ អ្នកគិតត្រូវបង្កើតជាឧទាហរណ៍មួយ ពីព្រោះឧទាហរណ៍នេះអាចជាតំណាងមួយនៃបញ្ហាទាំងឡាយដែលកំពុងចោទសួរ ។ ជោគជ័យនៃការគិតគូរពឹងផ្អែកទៅលើលទ្ធភាពក្នុងការកំណត់ឲ្យបានច្បាស់លាស់នូវធាតុផ្សំនៃការគិតគូរតាមរយៈការសួរសំណួរដែលផ្តោតទៅលើធាតុផ្សំទាំងនោះ ។ ហេតុនេះ វិធីសាស្ត្រដ៏ល្អបំផុតមួយក្នុងការសួរសំណួរគឺត្រូវផ្តោតទៅលើធាតុផ្សំនៃការលើកហេតុផល ឬផ្តោតទៅលើផ្នែកមួយចំនួននៃការគិតគូរ ។

ក្នុងពេលបង្កើតសំណួរ គួរពិចារណាទៅលើសេចក្តីណែនាំ និងសំណួរគំរូដូចខាងក្រោម ៖

១) គោលបំណង ៖ រាល់គំនិតទាំងអស់វាបង្ហាញឲ្យឃើញអំពីគោលបំណងមួយ ហើយមិនអាចត្រូវបានយល់ឲ្យបានច្បាស់មុនពេលយល់អំពីគោលគំនិតនៃការគិតគូរនេះជាមុនសិន ។ សំណួរមួយចំនួនដែលផ្តោតទៅលើគោលបំណងនៅក្នុងការគិតរួមមាន ៖

- តើអ្វីជាគោលបំណងដែលគេចង់បានក្នុងពេលនេះ?
- តើអ្វីជាគោលបំណងនៅពេលដែលសំណើនោះត្រូវបានបង្កើតឡើង?
- តើអ្នកណាជាអ្នកស្តាប់ និងតើអ្នកស្តាប់ទាំងនេះគួរត្រូវបញ្ចុះបញ្ចូលតាមវិធីណា?
- តើអ្វីជាគោលបំណងនៃកិច្ចការនេះ?
- តើអ្វីដែលកិច្ចការនេះចង់សម្រេចឲ្យបាន?

- តើអ្វីជាគោលបំណងសំខាន់ ឬកិច្ចការសំខាន់នៅក្នុងខ្សែសង្វាក់នៃគំនិតនេះ?

- តើអ្វីជាគោលបំណងនៅក្នុងជំពូកនេះ ទំនាក់ទំនង គោលនយោបាយ ច្បាប់នេះ?

- តើអ្វីជារបៀបវារៈសំខាន់? តើអ្វីជាគោលបំណងសំខាន់ផ្សេងទៀតដែលត្រូវពិចារណា?

២) សំណួរ ៖ គំនិតទាំងអស់គឺជាការឆ្លើយតបទៅនឹងសំណួរមួយ ។ សន្និដ្ឋានថា គ្មានគំនិតណាមួយដែលត្រូវបានយល់ឲ្យបានពេញលេញ ប្រសិនបើយើងមិនយល់អំពីសំណួរដែលបង្កឲ្យមានជាគំនិតនោះ ។ សំណួរទាំងឡាយដែលផ្តោតទៅលើការចោទសួរទៅលើការគិតគូរ រួមមាន ៖

- តើសំណួរដែលកំពុងលើកឡើងណាមួយដែលមិនសូវច្បាស់? ចូរពន្យល់ ។

- តើសំណួរណាខ្លះដែលបង្កឲ្យមានជាទង្វើបុគ្គលនៅក្នុងស្ថានភាពនេះ ឬនៅក្នុងស្ថានភាពផ្សេង?

- តើសំណួរនេះជាអ្វីដែលគួរផ្តោតនៅក្នុងពេលនេះឬទេ ឬមួយក៏មានសំណួរផ្សេងទៀតដែលគួរសួរ?

-សំណួរនៅក្នុងគំនិតរបស់ខ្ញុំគឺ ៖ តើអ្នកយល់ព្រម ឬមួយអ្នកមើលឃើញសំណួរផ្សេងទៀតដែលត្រូវសួរ?

- តើសំណួរគួរត្រូវសួរបែបនេះ ឬបែបណា?

- បើតាមទស្សនៈអភិរក្ស សំណួរគឺ... តាមទស្សនៈសេរី សំណួរគឺ... តើយើងត្រូវសួរបែបណាដែលជាវិធីសាស្ត្រដ៏ល្អបំផុត?

- តើសំណួរណាដែលគួរលុបចោល ហើយសំណួរណាដែលគួរសួរ?

៣) ព័ត៌មាន ទិន្នន័យ និងបទពិសោធន៍ ៖ គំនិតទាំងអស់គឺផ្តោតទៅលើព័ត៌មានជាមូលដ្ឋានមួយ ។ សន្មតថា គ្មានគំនិតណាមួយដែលត្រូវយល់បានច្បាស់ ប្រសិនបើព័ត៌មានជាមូលដ្ឋាន (ការពិត ទិន្នន័យ និងបទពិសោធន៍) ដែលទ្រទ្រង់ ឬពន្យល់ថា គំនិតនោះមានភាពច្បាស់លាស់ ។ សំណួរទាំងឡាយដែលផ្តោតទៅលើព័ត៌មាននៅក្នុងការគិតគូរ រួមមាន ៖

- តើព័ត៌មានណាដែលផ្តល់ជាមូលដ្ឋាននៅក្នុងការផ្តល់យោបល់?

- តើផ្អែកទៅលើបទពិសោធន៍ណាដែលទ្រទ្រង់ជំនឿនេះ? តើជំនឿនេះអាចកែប្រែបានឬទេ?

- តើមានភស្តុតាងណាដែលបញ្ជាក់ថា ព័ត៌មាននេះត្រឹមត្រូវ? តើវាអាចបញ្ជាក់បានទេ?

- តើមានព័ត៌មាន ឬទិន្នន័យណាដែលមិនទាន់ត្រូវបានពិចារណា?

- តើទិន្នន័យទាំងនេះពឹងផ្អែកទៅលើអ្វី? តើទិន្នន័យទាំងនេះគួរត្រូវបានអភិវឌ្ឍន៍តាមវិធីណា? តើសេចក្តីសន្និដ្ឋានផ្អែកទៅលើភស្តុតាងច្បាស់លាស់ឬទេ?

៤) ការទាញហេតុផល និងសេចក្តីសន្និដ្ឋាន ៖ គំនិតទាំងអស់ទាមទារឲ្យមានការទាញហេតុផល ការសន្និដ្ឋាន និងការបង្កើតអត្ថន័យ ។ សន្មតថា គ្មានគំនិតណាមួយដែលត្រូវបានយល់ពេញលេញ

ប្រសិនបើគ្មាននរណាម្នាក់យល់អំពីការទាញហេតុផលដែលបង្កឲ្យមានគំនិតនោះ ។ សំណួរទាំងឡាយដែលផ្ដោតទៅលើការទាញហេតុផលទៅការគិតពិចារណា រួមមាន ៖

- តើសេចក្ដីសន្និដ្ឋានត្រូវបានបង្កើតឡើងតាមវិធីណា?

- តើការទាញហេតុផលដែលបានប្រើប្រាស់ហើយនោះអាចពន្យល់បានដែរឬទេ?

- តើមានសេចក្ដីសន្និដ្ឋានផ្សេងទៀតដែលត្រឹមត្រូវដែរឬទេ?

- ប្រសិនបើមានការពិតបែបណាមួយ តើសេចក្ដីសន្និដ្ឋានណាដែលល្អបំផុត ។

៥) ទស្សនៈ និងគំនិត ៖ គំនិតទាំងអស់រួមបញ្ចូលការប្រើប្រាស់ទស្សនៈ ។ សន្មតថា គ្មានគំនិតណាមួយដែលអាចត្រូវបានយល់ឲ្យបានពេញលេញ ប្រសិនបើគ្មានអ្នកណាយល់អំពីទស្សនៈដែលផ្ដល់និយមន័យ និងការបង្កើតគំនិតនោះ ។ សំណួរទាំងឡាយដែលផ្ដោតទៅលើទស្សនៈនៃការគិតគូររួមមាន ៖

- តើអ្វីជាគំនិតសំខាន់ដែលបានប្រើប្រាស់នៅក្នុងការទាញហេតុផលនេះ? តើគំនិតនេះអាចត្រូវបានពន្យល់ដែរឬទេ?

- តើទស្សនៈដែលកំពុងចោទគួរត្រូវលើកមកដោះស្រាយ ឬបញ្ហាគួរត្រូវបង្កើតសាជាថ្មី?

- តើការពិត និងការគិតគូរសាថ្មីបន្ថែមទៀតមានការចាំបាច់ដែរឬទេ?

- តើសំណួរនេះជាសំណួរផ្នែកច្បាប់ សំណួរបែបសាសនា ឬសំណួរផ្នែកសីលធម៌?

៦) ការសន្មត ៖ គំនិតទាំងអស់ផ្អែកទៅលើការសន្មតណាមួយ ។ សន្មតថា គ្មានគំនិតណាមួយដែលអាចត្រូវបានយល់ឲ្យបានពេញលេញ ប្រសិនបើគ្មាននរណាយល់ថា វាបានសន្មតទៅលើអ្វី ។ សំណួរទាំងឡាយដែលផ្ដោតទៅលើការសន្និដ្ឋានទៅលើការគិតគូរ រួមមាន ៖

- តើអ្វីដែលត្រូវគេមិនសូវចាប់អារម្មណ៍?

- ហេតុអ្វីបានជាការសន្មតបែបនោះត្រូវបានធ្វើឡើង? តើយើងគួរសន្និដ្ឋានបែបនោះឬ...?

- តើការសន្និដ្ឋានបែបណាដែលជាគ្រឹះនៃគំនិតចម្បង? តើការសន្និដ្ឋានអ្វីផ្សេងទៀតដែលគួរធ្វើឡើង?

៧) ផលប៉ះពាល់ និងលទ្ធផល ៖ គំនិតទាំងអស់ត្រូវបានបង្កើតឡើងទៅតាមទិសដៅណាមួយ ។ វាមិនត្រឹមតែចាប់ផ្ដើមពីចំណុចមួយ (នៅក្នុងការសន្និដ្ឋាន) វាថែមទាំងធ្វើដំណើរទៅកាន់ចំណុចមួយទៀត (លទ្ធផល) ។ សន្មតថា គ្មានគំនិតណាមួយដែលត្រូវបានយល់ឲ្យបានពេញលេញ ប្រសិនបើគ្មាននរណាយល់អំពីផលប៉ះពាល់ និងលទ្ធផលសំខាន់បំផុតដែលចេញពីគំនិតនោះ ។ សំណួរទាំងឡាយដែលផ្ដោតទៅលើផលប៉ះពាល់នៃការគិតគូររួមមាន ៖

- តើអ្វីដែលត្រូវគេគិតដល់ នៅពេលដែលគេនិយាយអំពីអ្វីម៉្យាង?

- ប្រសិនបើមនុស្សម្នាក់ធ្វើបែបនេះ តើអ្វីនឹងកើតឡើងជាលទ្ធផល?

- តើអ្វីជាផលប៉ះពាល់ដែល...?

- តើផលប៉ះពាល់នៃគោលនយោបាយនេះ ឬការអនុវត្តនេះត្រូវបានពិចារណាហើយឬនៅ?

៨) ទស្សនៈ ៖ គំនិតទាំងអស់កើតឡើងនៅក្នុងទស្សនៈណាមួយ ។ សន្មតថា គ្មានគំនិតណាមួយដែលត្រូវបានយល់ឲ្យបានពេញលេញ ប្រសិនបើគ្មាននរណាយល់អំពីទស្សនៈដែលបានបង្កើតវាឡើង ។ សំណួរទាំងឡាយដែលផ្តោតទៅលើទស្សនៈនៅក្នុងការគិត រួមមាន ៖

- តើទស្សនៈណាដែលគេបង្កើតឡើង?

- តើមានទស្សនៈផ្សេងទៀតដែលគួរពិចារណាឬទេ?

- តើទស្សនៈទាំងឡាយណាមួយដែលស័ក្តិសមជាងគេនៅក្នុងស្ថានភាពមួយ?

## សេចក្តីបញ្ចប់

នៅក្នុងទំព័របន្ទាប់ យើងនឹងបង្ហាញអំពីទស្សនៈជាមូលដ្ឋានបន្ថែមទៀតនៅក្នុងការត្រិះរិះពិចារណា និងពន្យល់អំពីសំណួរផ្សេងទៀតដែលអាចបង្កើតឡើង តាមរយៈការយល់ដឹង និងការប្រើប្រាស់មូលដ្ឋានទាំងនោះ ។ នៅពេលគ្រូបង្រៀនប្រើប្រាស់ឧបករណ៍នៃវិធីសាស្ត្រត្រិះរិះពិចារណានៅក្នុងការសន្ទនាបែបសូក្រាត ការពិភាក្សាបានក្លាយទៅជាមានទ្រង់ទ្រាយច្បាស់លាស់ និងមានលទ្ធផលល្អ ហើយសិស្សអាចយល់អំពីសារសំខាន់អំពីការសួរសំណួរនៅក្នុងការរៀនសូត្រ ។ បន្ទាប់មក សិស្សអាចបង្កើតជាសំណួរធំៗផ្សេងទៀតនៅក្នុងថ្នាក់រៀន និងនៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន ។

*(Linda Elder គឺជានាយកប្រតិបត្តិនៃវិទ្យាស្ថានអភិវឌ្ឍន៍ផ្នែកស្រាវជ្រាវ និងការផ្សារ ហើយ Richard Paul គឺជានាយកនៃមជ្ឈមណ្ឌលសម្រាប់ការត្រិះរិះពិចារណានៃសាកលវិទ្យាល័យសូណូម៉ា រដ្ឋកាលីហ្វ័រញ៉ា)* ។